# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្រាវជ្រាវកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

១. សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២. ឯកឧត្តម **ជា សុផារ៉ា** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៣. ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៤. ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥. ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

៦. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៧. ឯកឧត្តម **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ សមាជិក

៨. ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៩. រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១០. ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

១១. ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១២. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៣. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៤. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៥. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម សមាជិក

១៦. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិក

១៧. រដ្ឋលេខាធិការក្រសួងផែនការ សមាជិក

១៨. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៩. រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២០. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក

២១. រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២២. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

២៣. រដ្ឋលេខាធិការក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

២៤. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

២៥. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

២៦. រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

២៧. រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក

| | | |
|---|---|---|
| ២៨. រដ្ឋលេខាធិការក្រសួងកិច្ចការនារី | | សមាជិក |
| ២៩. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ៣០. ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣១. ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៣២. ឯកឧត្តម **ឃួន ស្រេង** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៣៣. ឯកឧត្តម **ម៉ៅ ភិរុណ** | អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ៣៤. ឯកឧត្តម **ឌី សំណាង** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៣៥. ឯកឧត្តម **ឡាយ វណ្ណៈ** | អភិបាលនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ៣៦. ឯកឧត្តម **ឈួរ ច័ន្ទឿន** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៣៧. ឯកឧត្តម **ជា សុមេធី** | អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ៣៨. ឯកឧត្តម **គួច ចំរើន** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| ៣៩. ឯកឧត្តម **ស្វាយ សំអ៊ាង** | អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៤០. ឯកឧត្តម **ថង សាវុន** | អភិបាលនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ៤១. ឯកឧត្តម **សួស ប្រាថ្នា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និង ខេត្ត នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៤២. ឯកឧត្តម **សេង យូអ៊ាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ផ្នែករដ្ឋបាលស៊ីវិល) នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៤៣. លោក **អ៊ួង ចន្ធី** | ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៤៤. លោក **គាន់ សំណាង** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការស្រាវជ្រាវកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- សម្របសម្រួល លើកសំណើដោះស្រាយអំពីបញ្ហាព្រំប្រទល់រដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនទាន់ច្បាស់លាស់
- សិក្សាស្រាវជ្រាវ លើកសំណើកែសម្រួលព្រំប្រទល់រដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន
- សិក្សាស្រាវជ្រាវ លើកសំណើសុំបង្កើត ឬកែសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្តែកលើកត្តាភូមិសាស្រ្ត ប្រជាសាស្រ្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន
- ធ្វើរបាយការណ៍ជាប្រចាំជូនរាជរដ្ឋាភិបាលអំពីការរៀបចំកែសម្រួលព្រំប្រទល់រដ្ឋបាល និងបង្កើត កែសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៣.-**

គណៈកម្មការអាចបង្កើតអនុគណៈកម្មការបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

គណៈកម្មការអាចប្រើប្រាស់មន្ត្រីនៃក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឲ្យជួយការងាររបស់ខ្លួនតាមការចាំបាច់។

**ប្រការ ៤.-**

អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានគណៈ-កម្មការ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១១ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ